ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០២.សណន

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២

# សេចក្តីណែនាំ

## ស្តីពី

## ការដាក់អោយអនុវត្តន៍ ការប្រើប្រាស់អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ថ្នាក់ ខេត្ត ក្រុង

យោងសារាចរលេខ ១៤.ស.រ.ណ.ន ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ ។

មកដល់បច្ចុប្បន្ននេះ ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស បានបញ្ចប់ជាស្ថាពរ និងទទួលបានលទ្ធផលល្អប្រសើរ ។ លទ្ធផលទាំងនេះ បានមកពីការចូលរួមសហការ និងការយកចិត្តទុកដាក់អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ របស់ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង និងមន្ត្រីពាក់ព័ន្ធទាំងអស់ ដែលជាសក្ខីភាពបញ្ជាក់អោយឃើញ នូវការអនុវត្តន៍គោលនយោបាយកែទំរង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ។

ចំពោះមុខនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នឹងដាក់អោយអនុវត្តការប្រើប្រាស់អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលដែលជាសមិទ្ធផលនៃការធ្វើជំរឿន ។ ដើម្បីអោយការអនុវត្តន៍នេះ ទទួលបានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ :

១- អត្តសញ្ញាណប័ណ្ណ នឹងត្រូវផ្តល់ជូនដល់មន្ត្រីរាជការស៊ីវិលទាំងឡាយណា ដែលបានផ្តិតយកស្នាមមេដៃ ថតរូប តាមប្រព័ន្ធកុំព្យូទ័រ និងមានឈ្មោះនៅក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធពតិមានវិទ្យា នៅតាមសាលាខេត្ត ក្រុង និងមន្ទីរជុំវិញខេត្ត ក្រុង ។

២- នៅជំហានដំបូង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នឹងចេញអត្តសញ្ញាណប័ណ្ណជូនតែមន្ត្រីរាជការទាំងឡាយណា ដែលស្ថិតនៅក្នុងប្រភេទជាមន្ត្រីសកម្ម ហើយកំពុងបំរើការងារនៅតាមសាលាខេត្ត ក្រុង និងមន្ទីរជំនាញជុំវិញខេត្ត ក្រុង ។

៣-ចំពោះមន្ត្រីរាជការដែលជាមន្ត្រីសកម្មដែរ ប៉ុន្តែកំពុងស្ថិតនៅក្នុងស្ថានភាពផ្សេងៗដូចជា មន្ត្រីផ្ទេរចេញ ផ្ទេរចូល មន្ត្រីនិយ័តកម្ម មន្ត្រីដល់អាយុចូលនិវត្តន៍ ឬមន្ត្រីដែលស្នើសុំកែតំរូវពតិមានផ្សេងៗ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នឹងចេញអត្តសញ្ញាណប័ណ្ណជូនជាបន្តបន្ទាប់ ក្រោយពេលពិនិត្យផ្ទៀងផ្ទាត់រួចហើយ ។

៤-មន្ត្រីរាជការដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ស្ថិតនៅក្រៅក្របខ័ណ្ឌដើម មន្ត្រីជាប់បំពេញបេសកកម្មក្នុងនិងក្រៅប្រទេស មន្ត្រីកំពុងបំពេញកម្មសិក្សា មន្ត្រីក្របខ័ណ្ឌថ្មី និងពុំទាន់មានឈ្មោះក្នុងតារាងទូទាត់បៀវត្ស និង មន្ត្រីដែលស្ថិតក្នុងភាពមិនប្រក្រតីផ្សេងៗ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នឹងចេញអត្តសញ្ញាណប័ណ្ណជូននៅពេលណា ដែលមន្ត្រីទាំងនេះបានចូលបំរើការងាររដ្ឋជាធម្មតាវិញ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់នៃច្បាប់ ។

៥-ចំពោះមន្ត្រីរាជការស៊ីវិលដែលបានទទួលមរណៈភាព បានបោះបង់ចោលការងារ បានសុំលាឈប់ពីការងារ មន្ត្រីដែលត្រូវបានក្រសួង ស្ថាប័ន លុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋ និងមន្ត្រីដែលកំពុងជាប់ទណ្ឌកម្ម ឬជាប់ពិរុទ្ធ មន្ត្រីបាត់បង់សមត្ថភាពពលកម្ម មានជំងឺរ៉ាំរ៉ៃ និងមន្ត្រីដែលមានប្រកាសចូលនិវត្តន៍ ហើយមិនត្រូវបានផ្តល់អត្តសញ្ញាណប័ណ្ណជូនឡើយ ។

៦-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល នឹងធ្វើលិខិតជូនដំណឹងដោយឡែក ចំពោះខេត្ត ក្រុងនីមួយៗអំពីកម្មវិធីនៃការទទួលយកអត្តសញ្ញាណប័ណ្ណពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីធ្វើការបែងចែកជូនមន្ត្រីរាជការ ។

៧-នៅពេលប្រគល់អត្តសញ្ញាណប័ណ្ណជូនមន្ត្រីរាជការ ខេត្ត ក្រុង និងមន្ទីរជំនាញ ត្រូវធ្វើការពន្យល់ណែនាំ និងតម្រូវអោយសាមីមន្ត្រីចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណរបស់ខ្លួន និងលើបញ្ជីឈ្មោះផ្លូវការដោយ ប៊ិចមានទឹកខ្មៅពិសេស ដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបាន ផ្តល់ជូនជាគំរូ ។

៨-សាលាខេត្ត ក្រុង និងមន្ទីរជំនាញទាំងអស់ត្រូវបញ្ជូនត្រឡប់មកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលវិញ នូវបញ្ជីឈ្មោះនិងអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការរបស់ខ្លួន ដែលបានទទួលមរណៈភាព បានបោះបង់ចោលការងារ បានលាឈប់ពីការងារ ឬមន្ត្រីដែលត្រូវបានក្រសួងចេញប្រកាសលុបឈ្មោះ ចេញពីក្របខ័ណ្ឌរដ្ឋ ។

៩-សាលាខេត្ត ក្រុង និងមន្ទីរជំនាញទាំងអស់ត្រូវធ្វើរបាយការណ៍បូកសរុប អំពីលទ្ធផលនៃការងារនេះហើយផ្ញើជូនអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ ។

ទទួលបានសេចក្ដីណែនាំនេះ សាលាខេត្ត ក្រុង និង មន្ទីរជំនាញ ទាំងអស់ត្រូវសហការ និងចាត់តាំងអនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រី
និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

ហ៊ុន សែន

បានជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សុខ អាន

**<u>កន្លែងទទួល:</u>**

- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ